# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៤១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី
## ការកំណត់តំបន់ការពារឡក្រុលាលភាជន៍បុរាណ សម័យអង្គរ នៅភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់ និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរអប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពារតំបន់ និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ "អប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការកែសម្រួល មាត្រា៤ និង មាត្រា៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពារតំបន់ និងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា"

- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- បានឃើញអនុក្រឹត្យលេខ ៩៦ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពី ការកែសម្រួលមាត្រា៦ និង មាត្រា១៤ នៃអនុក្រឹត្យលេខ ១៥.អនក្រ .បក. ចុះ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរអប្សរា

## សម្រេច

**មាត្រា ១.-**

ត្រូវបានកំណត់តំបន់ការពារស្ថានីយឡកុលាលភាជន៍បុរាណសម័យអង្គរ ស្ថិតនៅក្នុងភូមិតានី ឃុំរុនតាឯក ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។

**មាត្រា ២.-**

តំបន់ការពារស្ថានីយឡកុលាលភាជន៍បុរាណសម័យអង្គរនេះ មានផ្ទៃដីទំហំ **៣៤១.០០២ម$^2$ (បីរយសែសិបមួយពាន់ និង ពីរម៉ែត្រការ៉េ)** ស្ថិតនៅចន្លោះចំណុចកូអរដោនេភូមិសាស្ត្រ ដូចខាងក្រោម ÷

-ចំណុច **ក :** ខ្សែរយៈបណ្តោយ **៣៩២៦២៤** ខ្សែរយៈទទឹង **១៤៥០០៣០**
-ចំណុច **ខ :** ខ្សែរយៈបណ្តោយ **៣៩២៨២៤** ខ្សែរយៈទទឹង **១៤៥០០១៣**
-ចំណុច **គ :** ខ្សែរយៈបណ្តោយ **៣៩២៦២៤** ខ្សែរយៈទទឹង **១៤៥០៤៥៥**
-ចំណុច **ឃ :** ខ្សែរយៈបណ្តោយ **៣៩៣០៨១** ខ្សែរយៈទទឹង **១៤៥០៤៥៥**
-ចំណុច **ង :** ខ្សែរយៈបណ្តោយ **៣៩៣១៦៣** ខ្សែរយៈទទឹង **១៤៥១២០១**
-ចំណុច **ច :** ខ្សែរយៈបណ្តោយ **៣៩៣០១៥** ខ្សែរយៈទទឹង **១៤៥១២០១**
-ចំណុច **ឆ :** ខ្សែរយៈបណ្តោយ **៣៩២៨៧២** ខ្សែរយៈទទឹង **១៤៥១០០១**
-ចំណុច **ជ :** ខ្សែរយៈបណ្តោយ **៣៩២៦២៤** ខ្សែរយៈទទឹង **១៤៥០៥៧១**

ដូចមានផែនទីបង្ហាញទីតាំងនៅក្នុងឧបសម្ព័ន្ធ១ និង ឧបសម្ព័ន្ធ២ ។

**មាត្រា ៣.-**

អាជ្ញាធរអប្សរាត្រូវទទួលបន្ទុកគ្រប់គ្រង ថែរក្សា ការពារ និងរៀបចំផែនការអភិវឌ្ឍប្រកបដោយចីរភាព ស្របតាមទិសដៅរបស់រាជរដ្ឋាភិបាល នៅតំបន់ការពារស្ថានីយឡកុលាលភាជន៍បុរាណសម័យអង្គរ ដូចមានចែងក្នុង **មាត្រា២** ដើម្បីជួយលើកតម្កើងជីវភាពរបស់ប្រជាពលរដ្ឋនៅភូមិតានី និង ភូមិធម្មជាតិ នៃតំបន់អភិវឌ្ឍន៍រុនតាឯក ព្រមទាំងភូមិដទៃទៀតនៅក្បែរតំបន់នេះ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានអាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមហត្ថលេខា

**ប្រធានអាជ្ញាធរអប្សរា**

សុខ អាន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ


Angkor GIS of Royal Angkor Foundation 1995
Potter/EFEO 1999
Project : WGS_1984_UTM_Zone_48N




| ចំណុច | ខ្សែរយៈទទឹង | ខ្សែរយៈបណ្ដោយ |
|---|---|---|
| ក | ៣៩២៦២៤ | ១៤៩០០៣០ |
| ខ | ៣៩២៨២៤ | ១៤៩០០១៣ |
| គ | ៣៩២៨២៤ | ១៤៩០៤៥៥ |
| ឃ | ៣៩៣០៨១ | ១៤៩០៤៥៥ |
| ង | ៣៩៣១៦៣ | ១៤៩១២០១ |
| ច | ៣៩៣០១៩ | ១៤៩១២០១ |
| ឆ | ៣៩២៨៧២ | ១៤៩១០០១ |
| ជ | ៣៩២៦២៤ | ១៤៩០៥៧១ |

នាយកដ្ឋានមណ្ឌលដ្ឋាន និងបុរាណវិទ្យាទី២

កែសម្រួលពីទិន្នន័យ

Pottier/EFEO 1999

*Project : WGS_1984_UTM_Zone_48N*